# កិច្ចព្រមព្រៀង

## រវាង

## រោងចក្រ ស្កាយវើត ហ្វេសិន (ខេមបូឌា) ឯ.ក

## ស្តីអំពីការព្យួរកិច្ចសន្យាការងារ

នៅថ្ងៃទីមួយ ខែកញ្ញា ឆ្នាំពីរពាន់ម្ភៃបី វេលាម៉ោងដប់ និងប្រាំនាទីព្រឹក នៅរោងចក្រ ស្កាយវើត ហ្វេសិន (ខេមបូឌា) ឯ.ក មានកិច្ចប្រជុំពិភាក្សា រវាងតំណាងក្រុមហ៊ុន ប្រតិភូបុគ្គលិក និងថ្នាក់ដឹកនាំ សហជីព-ទឹកចិត្តកម្មករកម្ពុជាប្រចាំរោងចក្រ ក្រោយពីប្រជុំពិភាក្សាស្តីអំពីការព្យួរកិច្ចសន្យាការងារ ភាគីទាំងពីរបានយល់ព្រមព្រៀងគ្នា ដូចខាងក្រោម៖

១- ភាគីទាំងពីរយល់ព្រមព្យួរការងារកម្មករនិយោជិតចំនួន ៤១០នាក់ (ស្រី ៣០៨នាក់) រយៈពេល ៤២ថ្ងៃ ចាប់ពីថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០២៣ ដល់ ថ្ងៃទី២១ ខែតុលា ឆ្នាំ២០២៣ ។

- ភាគីទាំងពីរ បានឯកភាពគ្នា និង ព្រមទទួលប្រាក់ឧបត្ថម្ភក្នុងការព្យួរកិច្ចសន្យាការងារ ចំនួន ៣០ដុល្លា ព្យួរកិច្ចសន្យាការងារចំនួន ២០ថ្ងៃ ចាប់ពីថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០២៣ ដល់ ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២៣។
- ភាគីទាំងពីរ បានឯកភាពគ្នា និងព្រមទទួលប្រាក់ឧបត្ថម្ភក្នុងការព្យួរកិច្ចសន្យាការងារ ចំនួន ៣០ដុល្លា ព្យួរកិច្ចសន្យាការងារចំនួន ២២ថ្ងៃ ចាប់ពីថ្ងៃទី១ ខែតុលា ឆ្នាំ២០២៣ ដល់ ថ្ងៃទី២២ ខែតុលាឆ្នាំ២០២៣ ។

២-កម្មករនិយោជិត ត្រូវត្រឡប់មកធ្វើការវិញ នៅថ្ងៃទី២៣ ខែតុលា ឆ្នាំ២០២៣ ក្នុងករណី កម្មករនិយោជិតណាមិនបានចូលធ្វើការវិញនោះទេ ក្រុមហ៊ុននឹងអនុវត្តតាមច្បាប់ស្តីពីការងារ និងបទបញ្ជាផ្ទៃក្នុងក្រុមហ៊ុន ។

ប្រាក់ឧបត្ថម្ភលើក១ បើកនៅថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០២៣ និងលើកទី២ នៅថ្ងៃទី២៥ ខែតុលា ឆ្នាំ២០២៣។

កិច្ចព្រមព្រមព្រៀមនេះ ចាប់អនុវត្ត នឹងមានប្រសិទ្ធិភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ថ្ងៃសុក្រ ១រោច ខែស្រាពណ៍ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០២៣

ហត្ថលេខានិងត្រាក្រុមហ៊ុន

ក្រុមហ៊ុន ស្កាយវើត ហ្វេសិន (ខេមបូឌា) ឯ.ក
SKYWORTH FASHION (CAMBODIA) CO.,LTD.
KINGDOM OF CAMBODIA

មី លីចភ្វាន

ស្នាមមេដៃតំណាងកម្មករ និងសហជីព

ខេង វណ្ណា　ប៉ាត សុខា　ស្រ៊ុន ស្រឿន

យ៉ត មករា　ភាព ជីវ័ន្ត　ស្រឿន ធី